Reading Book

# ពិភពរឿងនិទាន

*The World of Stories*



# សុបិនកុមារ

# Soben Komar

ភាគ ១

47

**សៀវភៅជាឃ្លាំងនៃចំណេះដឹង**

*Books are the source of knowledge*

កាលដើមឡើយមានព្រះមហាក្សត្រមួយអង្គព្រះនាម **បរន្តបៈ** គ្រងរាជសម្បត្តិនៅនគរកោសម្ពី។ មហេសីព្រះនាម **កេសរមាលាទេវី** ប៉ុន្តែគ្មានព្រះរាជបុត្រមួយអង្គសោះ ក្នុងនគរនោះមានប្តីប្រពន្ធពីរនាក់ជាមហាសេដ្ឋី។ ក្រោយមក ពួកគាត់ក៏កើតបានកូនប្រុសមួយ តែចម្លែកណាស់ពេលដែលកូននោះកើតមកក្នុងថ្ងៃដំបូង គេញាំអាហារបានមួយវែក ថ្ងៃទីពីរញាំពីរវែក រហូតដល់អាយុមួយខែគេញាំអាហារដល់ទៅ៣០វែកទើបឆ្អែត។ សេដ្ឋីកំណាញ់ស្វិតនេះក៏កើតក្តីព្រួយបារម្ភណាស់ ព្រោះពួកគាត់ភ័យខ្លាចក្រលំបាកទៅថ្ងៃក្រោយ ទើបប្តីពិគ្រោះនឹងប្រពន្ធថា "កូនយើងនេះជាទារកចង្រៃអពមង្គលណាស់ បើចិញ្ចឹមវាតទៅទៀតទ្រព្យសម្បត្តិទាំងប៉ុន្មានមុខជាវិនាសហិនហោចដោយសារវាមិនខាន"។ ដូច្នេះពីរនាក់ប្តីប្រពន្ធក៏សម្រេចចិត្តបីកូនទៅដាក់ចោលនៅទីប៉ាឆា។



At an earlier time, there was a king named **Pakrontakpak** reigning in Korsampi Kingdom. He had a wife named **Kesar Mealea Devy**, but had no children. In this kingdom, there also lived a husband and a wife who were millionaires. Later his wife delivered a baby boy. Amazingly, on the first day of his birth, the baby boy was able to eat a ladleful of food; the second day, two ladlefuls and one month, thirty ladlefuls. Soon, the stingy millionaires were frantic with worry for fear that they would at a future time become poor. "Our son is a very unfortunate baby," the husband talked to his wife, "if we still continue to raise him, our wealth will be lost because of him." Therefore, the husband and wife decided to abandon him at a crematorium.



លុះវិលងអាធ្រាត្រ មានព្រះថេរៈមួយអង្គបានយល់សប្តិឃើញចម្លែក ថាមានកូនដំរីសមួយចូលមកក្នុងអារាម ហើយមានមហាជន និងឥស្សរជនហែហមចោមរោមជាអនេក។ លុះព្រះថេរៈតើនឡើងពីសឹងនិមន្តទៅទីប៉ាឆា ស្រាប់តែឃើញទារកកំពុងស្រែកយំក៏បីទារកនោះទៅទុកក្នុងកុដិ។ លុះពេលភ្លឺស្វាងឡើងលោកនិមន្តទៅទទួលចង្ហាន់បិណ្ឌបាត្រក្នុងរាជត្រកូល។ ព្រះរាជាទ្រង់បានប្រគេនចង្ហាន់ដ៏ប្រណិតដល់ព្រះថេរៈៗបានថ្វាយព្រះពរទូលថា "បពិត្រមហារាជអាត្មាភាពរើសបានទារកម្នាក់នៅទីប៉ាឆា មិនដឹងជាអ្នកណាយកមកផ្តងចោលទេ"។ ព្រះរាជាសណ្តាប់ហើយ ក៏ទ្រង់ចាត់ម៉ែដោះឱ្យទៅទទួលទារកនោះយកមកចិញ្ចឹមបីបាច់ថែរក្សា។ ព្រះថេរៈឱ្យឈ្មោះទារកនោះថា "**ចៅសុបិនកុមារ**"។

At midnight, there was a monk who lived in the pagoda where the crematorium located had a strange dream. He dreamt of having a white baby elephant accompanied by a big crowd of folks and dignitaries walking into his pagoda. Waking up, he went to crematorium, then he saw the baby crying. He right away carried the baby in his arms and brought him to stay in his monastery. Next morning, he went to collect food from a royal family. The king offered auspicious food to the monk. The monk then said to the king, "I found a baby boy in the crematorium, My majesty! not knowing who abandoned him." Then the king had a wet nurse fetch the baby to take care of. The monk named the baby **Chao Soben Komar** – a kid as dreamt.



លុះ **ចៅសុបិនកុមារ** បានអាយុ៧ឆ្នាំ ព្រះថេរៈក៏ទៅទទួលយកមកបំបួសជាសាមណេរបង្ហាត់បង្រៀនព្រះបរិយត្តិដែលជាគោលសិក្សានៃព្រះពុទ្ធសាសនា។ មិនយូរប៉ុន្មាន សាមណេរ **សុបិន** មានប្រាជ្ញាឈ្លាសវៃ មានស្មារតីចងចាំ និងចេះដឹងក្នុងគម្ពីរព្រះត្រៃបិដក។ លុះសាមណេរមានព្រះជន្ម២០ព្រះវស្សា ព្រះថេរៈបានទូលព្រះរាជាថា "សាមណេរ **សុបិន** មានអាយុគួរនឹងឧបសម្បទបានហើយ សូមព្រះអង្គព្រះរាជទានត្រៃចីវរ និងបរិក្ខាផ្សេងៗដើម្បីឧបសម្បទជាភិក្ខុ"។ ព្រះរាជាទ្រង់ចាត់គ្រឿងសមណបរិក្ខារសព្វគ្រប់ហើយ ទ្រង់ចាត់អាមាត្យឱ្យយកទៅប្រគេនព្រះថេរៈឯអារាម។ **សុបិន** សាមណេរក្រោយពីបានឧបសម្បទជាភិក្ខុភាវៈក្នុងព្រះពុទ្ធសាសនាហើយ ក៏មានកិត្តិនាមល្បីថា លោកជាអ្នកទ្រទ្រង់ព្រះត្រៃបិដកជាធម្មកថិកស្ទាត់ជំនាញក្នុងការបកស្រាយធម៌វិន័យបានក្បោះក្បាយល្អណាស់ លោកតែងតែនិមន្តទៅទទួលចង្ហាន់បិណ្ឌបាត្រក្នុងរាជត្រកូល។

When **Chao Soben Komar** was about 7 years old, the monk got him back from the royal family and ordained him a novice so that he could study Tripitaka, the ideological foundation in Buddhism. Not long, because he was intelligent and had good memory, novice, **Soben**, knew everything in the Tripitaka. When the novice was at the age of 20, the monk went to the king and said, "Novice **Soben** was old enough to become a **Bhikkhu**- high class monk, so we needed robes and other materials to ordain him as a **Bhikkhu**. Having had enough materials, the king had them taken to the monk in the pagoda. Novice Monk **Soben**, having been ordained as **Bhikkhu**, was very famous, for he was a supporter of the Tripitaka, a well-versed preacher who was able to interpret Buddhist Discipline in great detail—and he would always go to get food from royal families.



លុះឧបសម្បទបាន៥វស្សា។ នៅរាត្រីមួយ **សុបិន** ភិក្ខុបានសុបិននិម្មិតយ៉ាងចម្លែកណាស់ ថាខ្លួនលោកបានទៅស្ថិតនៅលើកំពូលភ្នំហិមពាន្ត ហើយបានចាប់មណ្ឌលព្រះអាទិត្យដាក់លើព្រះហស្តស្តាំ ហើយចាប់មណ្ឌលព្រះចន្ទដាក់លើព្រះហស្តឆ្វេង មានមហាជនជាច្រើននាំគ្នាចូលមកកកកុញធ្វើសក្ការបូជាដល់លោកក្រាបសំពះដោយក្តីគោរព។ ដល់ភ្លឺស្វាង **សុបិន** ភិក្ខុតើនឡើងបានធ្វើកិច្ចដល់ឧបជ្ឈាយាចារ្យនូវដំណើររឿងយល់សប្តិដែលលោកបានឃើញក្នុងពេលរាត្រីនោះ។ លោកគ្រូអាចារ្យពិចារណាថា "**សុបិន** ភិក្ខុនេះមុខជាបានគ្រងរាជសម្បត្តិជាស្តេចឯករាជ្យប្រកបដោយឫទ្ធិចេស្តាបារមីល្បីខ្ចរខ្ចាយ" ហើយលោកចូលទៅកាន់រាជត្រកូលដើម្បីទទួលចង្ហាន់បិណ្ឌបាត្រ និងបានដំណាលរឿងសុបិននោះថ្វាយព្រះរាជា ជាទីសណ្តាប់ផង។

5 years later, one day **Bhikkhu Soben** had a strange dream. He dreamt about his body being at the top of Himalayas Mount; he could catch the sun and held it in his right palm and the moon in his left palm, and crowded people came to pay their respect before him. In the morning, **Bhikkhu Soben** went to his higher monk and told him about his dream last night. "**Bhikkhu Soben** is going to become a famous and powerful king," thought the higher monk. Then the monk went to the royal family for food and right away told the king about **Soben's** dream.



ព្រះរាជាទទួលដំណឹងនេះហើយ កៅបញ្ជាឱ្យហោរាចូលគាល់ត្រាស់សួរអំពីសុបិននិម្មិតនេះ។ ហោរាបានថ្វាយទំនាយថា "សូមទ្រង់មេត្តាប្រោស **សុបិន** ភិក្ខុនោះតទៅនឹងជាអ្នកមានឫទ្ធិល្បីល្បាញហើយបានគ្រងរាជជាស្ដេចឯករាជ្យ"។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ដូច្នេះហើយ ទ្រង់មានព្រះតំរិះថា "**សុបិន** ភិក្ខុមុខជាដណ្ដើមរាជបល្ល័ង្កអញមិនខាន បើដូច្នេះ អញគួរតែចាត់ការវាជាមុន" ហើយទ្រង់បញ្ជាអាមាត្យឱ្យទៅចាប់**សុបិន**ភិក្ខុផ្សឹកចេញឃុំខ្លួនទុកក្នុងគុក។

Then the king invited a prophet and asked him about that dream. "My majesty! **Soben** will have great power," predicted the prophet, "and became an independent king." After listening to the prophecy, the king thought that, "**Bhikkhu Soben** is going to seize the throne, so I have to ruin him beforehand." The king ordered his royal soldiers to arrest **Bhikkhu Soben** and kept him in jail.



ថ្ងៃមួយព្រះរាជាចេញទៅក្រសាលតាមដងទន្លេជាមួយនឹងស្រីស្នំ ព្រមទាំងអាមាត្យសព្វមុខមន្ត្រីដោយហ៊ុំទន្លេនឹងសំណាញ់ក្នុងទឹកទើបស្ដេចចុះក្រសាលជាមួយស្រីស្នំទាំងឡាយ។ ក្រោយពីស្ដេចឡើងមកវិញពួកព្រានប្រមូលសំណាញ់ចេញ ស្រាប់តែជាប់កម្រងផ្កាមួយហើយយកទៅថ្វាយស្ដេចៗដេញដោលសួររកម្ចាស់កម្រងផ្កានេះ តែគ្មាននរណាដឹងឡើយ។ ទើបទ្រង់មានព្រះតម្រិះយល់ឃើញថា កម្រងផ្កានេះប្រហែលជារបស់នារីដែលមានបុណ្យវាសនាខ្ពង់ខ្ពស់ហើយ បានជារចនាក្នុងមាលាដ៏វិសេសដូច្នេះ" ទើបទ្រង់ចាត់អាមាត្យ និងពួកថ្មើរព្រៃឱ្យចេញទៅរកស្រុកទេសផ្នែកខាងលើទន្លេ ហើយស៊ើបសួររកនារីបញ្ចពិធកល្យាណីដើម្បីតំណែងជាព្រះអគ្គមហេសីរបស់ព្រះអង្គ។

One day the king had a visit along the river with his concubines, royal officials and soldiers. The king ordered fishermen to lay the fishing nets around the river before he went down to swim with his concubines. After the king walked upland, the fishermen picked up the fishing nets, in which a garland of flowers was found. They took the garland to the king. Then the king asked who had made this garland, but found no one. The king thought this garland must belong to a fortunate young lady because it was beautifully arranged. So, the king ordered his royal soldiers and hunters to look for her on the upper river in order to marry her.





អាមាត្យ និងពួកថ្មើរព្រៃនាំគ្នាត្រាច់រង្គាត់ឡើងតាមដងទន្លេទៅលើអស់កាលយូរអង្វែងឥតបានជួបប្រទះនឹងស្រុកណាមួយឡើយ។ ប៉ុន្តែពួកគេក៏បានទៅដល់លំនៅនៃស្តេចស្វាសដែលស្នាក់អាស្រ័យនៅលើដើមស្វាយក្បែរមាត់ទន្លេជាមួយនឹងបរិវារស្វារាប់មិនអស់។ ស្តេចស្វាសឃើញជនទាំងនោះមកឈប់ក្បែរគល់ស្វាយក៏សួរថា "អ្នកមកពីណា? ហេតុអ្វីបានជាមកដល់ទីនេះ? តើមានបំណងអ្វីទៅ?" ពួកអាមាត្យប្រាប់ស្វាថា "យើងមកកាន់ទីនេះ ព្រោះទទួលព្រះរាជបញ្ជាពីព្រះមហាក្សត្រឱ្យពួកយើងមកស៊ើបរកនារីបញ្ចពិធកល្យាណី តើអ្នកបានដឹងខ្លះៗដែរឬទេ?"។ ស្តេចស្វាសប្រាប់ថា "បើតាមខ្ញុំដឹងនៅខាងលើទន្លេនេះ មានរាជបុត្រីនៃព្រះរាជាមួយព្រះអង្គព្រះនាម **បុទុមកេសរា** ទ្រង់ឆោមល្អលើសនារីក្នុងលោកិយ នាងជានារីបញ្ចពិធកល្យាណីគង់នៅលើប្រាសាទ៧ជាន់ មានមនុស្សរក្សាការពារយ៉ាងម៉ឺងម៉ាត់ ជាបុត្រីរបស់ព្រះបាទ **កោមលរាជ** និងព្រះមហេសី **បុទុមវតីទេវី** នៅនគរចិន្តបុរីដែនខេមរដ្ឋ។ មានស្តេចមួយព្រះអង្គនាំគ្រឿងបណ្ណាការសុំស្តីដណ្តឹងព្រះរាជធីតានោះ តែព្រះវរបិតានាងមិនទាន់លើកឱ្យទៅស្តេចអង្គណានៅឡើយទេ"។ ជនថ្មើរជើងសួរទៀតថា "ចុះធ្វើដូចម្តេចនឹងបានទៅដល់នគរនោះ?" ស្តេចស្វាសប្រាប់ថា "បើធ្វើដំណើរតាមផ្លូវគោកពិបាកហើយឆ្ងាយណាស់ និងមានគ្រោះថ្នាក់ច្រើន។ បើធ្វើដំណើរតាមជើងទឹកទើបងាយស្រួលជាង"។

The servants of the king and his hunters went back and forth unceasingly along the river for ages, but found her nowhere. They finally arrived at a mango tree near the riverbank, where White Monkey King and his countless companies had lived. "Where are you from? Why are you here? And what do you want? " asked White Monkey King, seeing the royal servants and hunters resting near the base of mango tree. They replied, "We have been ordered by our king to seek for a lady of five beauties—hair, lips, teeth, skin and age? Have you heard about her?" "As far as I know, at the upper part of this river, there lived a daughter of a king named **Botom Kessora**, who is the most beautiful of all in the world. She lives in a 7-storeyed castle, strictly guarded by soldiers and is the daughter of King **Kormoleakreach** and Queen **Botomvatey Devy**, reigning in **Chentak Borei**, Kingdom of Cambodia. A king brought her some presents for engagement to her, but her father has refused to marry her to anyone." A hunter added, "How can we reach that kingdom?" "You will find it difficult, far and dangerous to take the road," answered White Monkey King, "while taking the waterway is much easier."



អាមាត្យបានទទួលព័ត៌មានពីស្តេចស្វាសដូច្នេះហើយ ក៏វិលត្រឡប់ទៅនគរវិញ ក្រាបទូលព្រះរាជាឱ្យទ្រង់ជ្រាប។ ទ្រង់បញ្ជាឱ្យរៀបចំសំពៅធំៗចំនួន៧ ក្នុងសំពៅនីមួយៗផ្ទុកដោយយោធា៥០០នាក់ព្រមទាំងភស្តុភា និងគ្រឿងសាស្ត្រាវុធផ្សេងៗ បើកសំពៅចេញទៅក្នុងមហាសមុទ្រអស់កំឡុងបីខែ ទើបទៅដល់នគរចិន្តបុរីដែនខេមរដ្ឋ។ នៅទីនោះមានកងយោធារបស់ស្តេច១០១ដែលបានទៅដល់មុនគេឮដំណឹងថា មានសំពៅចូលមកចងស្ពានមេត្រីដើម្បីស្តីដណ្តឹងព្រះរាជធីតាដូច្នេះ ក៏មិនពេញចិត្ត ទើបបណ្តាលឱ្យប្រយុទ្ធគ្នាឡើង។ យោធាសំពៅទាំង៧មិនអាចទប់ទល់នឹងកងយោធាទាំងនោះបានក៏បើកសំពៅគេចត្រឡប់ចូលនគរវិញ ទូលព័ត៌មានពីការបរាជ័យឱ្យទ្រង់បានជ្រាប។ ព្រះរាជាទ្រង់កើតទុក្ខព្រួយព្រះទ័យដោយចង់បាននាងកែវនោះខ្លាំងណាស់ ទ្រង់អត់ក្រយាស្ងោយផ្ទំសន្ធឹងសន្ធៃលើកាឡាព្រះបន្ទំ។ ព្រះមហេសីឃើញព្រះស្វាមីមានទុក្ខព្រួយបែបនេះក៏មានព្រះសុវណ្ណីថា "បើព្រះស្វាមីចង់បានព្រះនាងនោះមែន សូមទ្រង់ចាត់**បណ្ឌិតសុបិន** ឱ្យទទួលភារកិច្ចនេះចុះ ព្រោះល្បីថា ជាបណ្ឌិតមានប្រាជ្ញាឈ្លាសវៃណាស់នគេអាចទៅយកព្រះនាងនោះមកថ្វាយព្រះអង្គបាន។

Gaining the information from White Monkey King, the royal servants and hunters right away returned to their kingdom to tell the king. The king then ordered his servants to prepare seven big junks, each of which carried 500 soldiers, including weapons and other supplies, leaving for the ocean. The journey took three months to reach **Chentak Borei**, Kingdom of Cambodia. By the way, there were thousand soldiers of 101 kings who had desired to marry the princess too arriving earlier. They had been aware that there were junks of a king who also wished to get engaged to the princess coming, so they were not happy. They waged a battle against soldiers who were approaching. Unluckily, the soldiers in the seven junks could not defeat 101 soldiers, and they had to get back to their kingdom and told their king about their failure. The king, longing for the princess, was so sad that he could not eat but lay motionless in his bed. "If you really want to have her, order **Pundit Soben** to be responsible for it, since he had been famous for his deep wisdom, so he must be able to get her for you," said the Queen, seeing her husband was very sad.



ស្ដេចទ្រង់ព្រះសណ្ដាប់ហើយក៏ត្រាស់បង្គាប់អាមាត្យឱ្យទៅដោះលែង **ចៅសុបិន** ចេញពីគុក។ ព្រះអង្គបានសុំទោស **ចៅសុបិន** ដែលបានធ្វើទោសដោយជឿតាមពាក្យមួលបង្កាច់របស់អ្នកដទៃ ឥឡូវទ្រង់បានជ្រាបយ៉ាងច្បាស់ថា **ចៅសុបិន** គ្មានទោសអ្វីទេ។ ទ្រង់មានព្រះបន្ទូលលួងលោមដោយប្រការផ្សេងៗ ទ្រង់បានប្រទានគ្រឿងអលង្ការ និងលើកភោជនាហារមានឱជារសមកប្រទានដល់ **ចៅសុបិន** ហើយទ្រង់មានព្រះឱង្ការថា "**ចៅសុបិន!** នៅចិន្ដបុរីដែនខេមរដ្ឋមានព្រះរាជធីតាមួយអង្គប្រកបដោយរូបឆោមល្អឯកឥតមាននារីណាផ្ទឹមស្មើឡើយ ដូច្នេះចូរឯងលើកពលយោធាចុះសំពៅទៅកាន់ក្រុងចិន្ដបុរី ហើយរិះរកមធ្យោបាយយ៉ាងណានាំនារីកែវនោះមកថ្វាយយើងៗនឹងប្រទានរាជទ្រព្យជាទីគាប់ចិត្ត"។ **ចៅសុបិន** បានថ្វាយបង្គំទទួលភារៈនេះ ហើយវិលទៅកាន់អារាមលាគ្រូបាអាចារ្យ។ ពួកលោកបានឱ្យពរសព្ទសាធុការប្រសិទ្ធិពរជ័យដើម្បីចេញទៅធ្វើការនោះបានសម្រេច។

Having listened to the suggestion, the king got his servant to release **Chao Soben** from the jail. The king apologized to **Soben** for his punishment that he had imposed by believing the malignity of others. Now the king was aware that he was innocent. He comforted **Soben**, explaining several reasons and gave **Soben** jewelry and an auspicious food. "**Pundit Soben**!" Said the king, "At **Chentak Borei**, Kingdom of Cambodia, there is the most beautiful princess without peer, go with our soldiers by the junks to **Chentak Borei** and do whatever to get her to me; in return, I will give you as much wealth as you want." **Soben**, getting the gifts from the king, left for the pagoda to say goodbye to his priests. The priests wished him good luck to fulfill the duty.



**ចៅសុបិន** បន្ទាប់ពីបានទទួលពរពីលោកគ្រូហើយ ក៏ចុះសំពៅទៅជាមួយកងយោធា តែមុននឹងចេញដំណើរព្រះរាជាបានខ្សឹបប្រាប់ការណ៍សម្ងាត់ដល់អាមាត្យជំនិតថា "នែអាមាត្យ ! បើ **សុបិន** នាំព្រះរាជធីតាឡើងសំពៅបានហើយ ចូរឯងព្រួតដៃគ្នាចាប់វាទម្លាក់ទៅក្នុងមហាសមុទ្រឱ្យស្លាប់ទៅ ហើយសឹមនាំព្រះនាងមកថ្វាយយើង"។ អាមាត្យទទួលព្រះរាជបញ្ជាដោយក្ដីស្មោះស្ម័គ្រ។ លុះសំពៅ **ចៅសុបិន** បានទៅដល់កំពង់ផែចិន្តបុរីហើយក៏ប្រកាសថា សំពៅចូលមកលក់ទំនិញផ្សេងៗ សូមឱ្យបងប្អូនចូលមកមើលទំនិញនេះចុះ បើមានទំនិញលក់ក៏ខាងយើងទទួលទិញដែរ។ ពេលនោះធ្វើឱ្យសំពៅ **ចៅសុបិន** ចូលចតតាមកំពង់ផែឥតមានឧបសគ្គអ្វីឡើយ។ ហេតុដូចនេះ **ចៅសុបិន** ផ្ដាំអាមាត្យឱ្យនៅចាំសំពៅមិនឱ្យយោធាណាម្នាក់ឡើងគោកឡើយ។ **ចៅសុបិន** បានដើរទៅរកទីប្រជុំជនមួយក៏ឮអ្នកស្រុកនិយាយគ្នាថា នៅប្រាំពីរថ្ងៃទៀតព្រះរាជធីតា **បុទុមកេសរា** នឹងចេញទៅប្រពាតក្នុងសួនឧទ្យានហើយ។

**Chao Soben**, with the priests' blessings, went down to the junk with soldiers. "Soldiers! After **Soben** took the prince to the junk, you all kill him by dropping him into the ocean. Then you can brought the princess to me," the king whispered to the soldiers before the departure. The royal soldiers, with loyalty, kept the order. When **Soben**'s junk was at the harbor of **Chentak Borei**, the people in the junk announced that, "Our junk was coming to sell products; Please! Everyone, come and see our products. And if there are products that you all can sell to us, we'll buy them too." This made **Soben**'s junk be able to land at the harbor without any troubles. **Chao Soben** got the soldiers to wait in the junk: not allowing them to go on land. **Chao Soben** walked toward a crowd and heard villagers saying that the Princess **Botom Kessora** was going to take a stroll in the park in the next seven days.



ពេលនោះ **សុបិន** គិតថា "ធ្វើដូចម្ដេចនឹងបានជួបនឹងនាងទៅ បើមានគេការពារយ៉ាងម៉ឺងម៉ាត់ដូច្នេះ?" គិតហើយ **សុបិន** ម្ទីម្ទា ដើរទៅមើលក្នុងសួនឧទ្យានប្របនឹងឆ្នេរទន្លេ ក៏ស្រាប់តែបានជួបនឹងស្ដេចស្វាស១សំណេះសំណាលជាមួយ **សុបិន** ដោយការគួរសម។ **សុបិន** មើលអាកប្បកិរិយាស្ដេចស្វាសអាចពឹងពាក់បាន ក៏និយាយសុំជំនួយពីស្ដេចស្វាសរកមធ្យោបាយយ៉ាងណាឱ្យបានជួបនឹងព្រះនាង។ **សុបិន** បានស្នាក់នៅជាមួយស្ដេចស្វាសអស់ពីរ-បីថ្ងៃទើបមានដំណឹងថា ព្រះរាជធីតាទ្រង់យាងមកប្រពាតសួនឧទ្យាននៅព្រឹកថ្ងៃស្អែកនេះហើយ។

"How can I meet her, since there has been a strict guard?" thought **Chao Soben**. Then **Soben**, in a rush, went to the park along the riverbank and suddenly came across White Money King, who came to talk with **Soben** politely. Looking at his behavior and attitude, **Soben** found that the monkey dependable, so he asked for help from White Monkey King in order to find ways to meet the princess. A few days after his staying with White Monkey King, **Soben** knew that the princess was going to see the landscape in the park tomorrow morning.



លុះព្រលឹមស្រាងៗ **សុបិន** ចេញទៅរកកន្លែងលាក់ខ្លួនក្នុងសួនឧទ្យានជាមុន។ ពេលក្បួនដង្ហែមកដល់ខាងក្នុងកំពែងឧទ្យានហើយ ពួកនារីជាបរិវារប្រទ្បែងគ្នាលេងយ៉ាងទ្រហឹងអឺងកង ខ្លះរាំ ខ្លះច្រៀងយ៉ាងខ្ញៀវខ្ញា។ ឯព្រះរាជធីតាមិនបានលេងនឹងគេទេ ទ្រង់ទតមើលពួកគេហើយញញឹមប្រកបដោយព្រះភក្ត្រប្រិមប្រិយ។ ព្រះនាងមានឫកពារថ្លៃថ្នូរខ្ពង់ខ្ពស់សមតាមចរិយា ជាមួយរូបឆោមប្រកបដោយបញ្ចពិធកល្យាណីមែន។ **សុបិន** កាលបើបានឃើញព្រះរាជធីតាហើយក៏ចាប់ចិត្តស្នេហាយ៉ាងជ្រាលជ្រៅតែមិនអាចដឹងដល់ដួងហឫទ័យនៃព្រះនាងដូចម្ដេចឡើយ។ **សុបិន** អធិដ្ឋានថា "សូមបួងសួងដល់អារុក្ខអារក្សទេវតាទាំងឡាយ សូមឱ្យព្រះរាជធីតាទតឃើញរូបខ្ញុំតែម្នាក់បានហើយ សូមកុំឱ្យអ្នកដទៃមើលឃើញរូបខ្ញុំឱ្យសោះ" ថាហើយ **សុបិន** ចេញពីទីពួនបង្ហាញរូបរាងរបស់គេនៅចំពោះព្រះភក្ត្ររបស់ទ្រង់។

Next morning **Soben** went earlier to the park in hiding. Upon the march's arrival in the compound of the park, the ladies-in-waiting, the princess's servants, were having a great time: happily and noisily, some sang a song, and others danced. However, the princess, with a cheerful, charming smile, merely looked at them; she did not join them. Her perfect politeness was an excellent match with her outstanding beauty. **Soben**, when seeing the princess, felt deeply in love with her, but was not able to fully understand the princess's feeling. "May dryads help me and let only the princess see me," **Soben** prayed to the deity of the woods. Soon **Soben** turned up in front of the princess.



គ្រាន់តែព្រះនាងទតឃើញ **សុបិន** ភ្លាមក៏មានព្រះទ័យជ្រួលច្របល់រំជើបរំជួល ដោយសេចក្តីស្នេហាដែលមិនធ្លាប់មានពីមុនមក។ គូស្នេហ៍រវាងក្រមុំ និងកំលោះនេះបានកើតឡើងដោយអំណាចពីបុព្វេ គឺអ្នកទាំងពីរធ្លាប់រួមសុខរួមទុក្ខជាមួយគ្នាកាលពីជាតិមុន។ ព្រះនាងពេញព្រះទ័យនឹងបុរសនេះណាស់ តែព្រះនាងមិនទាន់ដឹងថា គេមានប្រាជ្ញាយ៉ាងណានោះទេ ទើបព្រះនាងធ្វើប្រស្នាគសាកល្បងប្រាជ្ញា។ ចំណែក **សុបិន** ក៏សំដែងកាយវិការឱ្យព្រះនាងបានដឹងថា គេបានយល់អំពីប្រស្នានេះហើយ។ រហូតដល់រសៀលព្រះសុរិយា ក្បួនដង្ហែបាននាំព្រះរាជធីតាត្រឡប់ចូលប្រាសាទវិញ។

No sooner did the princess see **Soben** than she excitedly fell in love with him, which she had never had this feeling before. The love of this young man and lady happened under the influence of their previous deed-- that is, in their previous lives, they had lived together as a family. The princess was genuinely fond of the young man, but did not know how clever he was; and therefore, she posed some enigma to trial his wisdom. Nonverbally, **Soben** showed the princess that he understood all her questions. At noon the march of the princess returned to her castle.



**សុបិន**បានត្រឡប់មកដល់លំនៅស្តេចស្វាស។ចុះពីលើដើមឈើសួ **សុបិន**អំពីដំណើរដែលបានទៅជួបនាង។ **សុបិន**បានពន្យល់ពីការទាក់ទងគ្នាដោយក្តីស្នេហារវាងព្រះរាជធីតាដោយប្រស្នាគដែលនាងបានសំដែង។ ស្តេចស្វាសសុំឱ្យ **សុបិន** ដោះប្រស្នាគនេះ។ **សុបិន** ប្រាប់ស្តេចស្វាសថា "កាលដែលព្រះនាងទតមកខ្ញុំ ទ្រង់បានចាប់ផ្កាឈូកមួយលើកថើបរួចឱបផ្កានោះមានន័យថា ព្រះនាងបានសំដែងសេចក្តីស្នេហាចំពោះរូបខ្ញុំ។ ព្រះនាងចាប់ផ្កាបង្វិលលើសិរសា៧ដងមានន័យថា ព្រះនាងនៅលើប្រាសាទ៧ជាន់។ ព្រះនាងចាប់ផ្កាមកថើបរួចដាក់ផ្កាទៅលើភ្លៅដូនចាស់ម្នាក់ ហើយយកមកថើបម្តងទៀតមានន័យថា តោងអាស្រ័យដូនចាស់ម្នាក់នោះទើបអាចចូលទៅរកព្រះនាងខាងក្នុងប្រាសាទបាន"។ ស្តេចស្វាសនិយាយថា "ប្រហែលជាយ៉ាងហ្នឹងមែនហើយ ចូរអ្នកទៅរកព្រះនាងនោះចុះ បើមានឧបសគ្គយ៉ាងណា ចូរអ្នកឱ្យដំណឹងមកខ្ញុំផង ខ្ញុំនឹងជួយឧបត្ថម្ភដល់អ្នកតាមការដែលអាចធ្វើទៅបាន។

At the shelter of White Monkey King, **Soben** was asked about his meeting with the princess. **Soben** told the White Monkey King about his love relationship with the princess through the third question she posed. King White Monkey asked **Soben** to answer this question. **Soben** explained, "When the princess was looking at me, she picked up a lotus to kiss and put her arms around it. This meant that she expressed love to me. Her raising the lotus and moving it around her head seven times meant that she stayed in a 7-storey castle. The fact that she kissed the lotus and put it on an old lady's thighs meant that through that old lady I could meet her in the castle." White Monkey King said, "It may be like that; go to meet her and let me know if you come across any obstacle. I will support you as much as I can."



លុះព្រឹកឡើង **សុបិន** លាស្តេចស្វាសដើរទៅនគរចិន្តបុរីចូលទៅសំពះជូនចាស់សុំស្នាក់នៅបានពីរ-បីថ្ងៃ។ ជូនចាស់ចិត្តសប្បុរសក៏យល់ព្រម ហើយបង្គាប់ទាសីឱ្យរៀបទីកន្លែងនឹងអាហារជូន **សុបិន** ពិសា។ ជូនចាស់បានសួរ **សុបិន** អំពីប្រវត្តិ និងគោលបំណងដែលបានមកកាន់ទីនេះ។ **សុបិន** ពោលសាសព្ទតាមរឿងគ្រប់យ៉ាងព្រមទាំងការបានជួបនឹងព្រះរាជធីតាក្នុងឧទ្យានទៀតផង។ ជូនចាស់មេអណ្តើកដែលបានយល់ពីព្រះរាជធីតាស្រាប់ក៏ជួយ **សុបិន** ឱ្យបានជួបព្រះនាងខាងលើប្រាសាទដូចបំណង ហើយក្រមុំកំលោះទាំងពីរបានពោលវាចាស្នេហាផ្អែមល្ហែមដែលមិនអាចបំភ្លេចបាន។ **សុបិន** បានទូលព្រះនាងថា "បងត្រូវចុះសំពៅនៅអាធ្រាត្រនេះហើយ តើព្រះនាងសុខចិត្តទៅជាមួយនឹងបងដែរឬទេ? ព្រះនាងត្រិះរិះស្ទាក់ស្ទើរក្នុងចិន្តាខ្លាចក្រែងព្រះវរមាតាបិតាកើតទុក្ខដោយហេតុព្រាត់ប្រាសអំពីបុត្រ តែព្រះនាងគិតអំពីអនាគតជាសំខាន់ ទើបទ្រង់កាត់ព្រះទ័យទៅតាមព្រះស្វាមី ហើយព្រះនាងប្រមូលរបស់របរមានតម្លៃផ្សេងៗចងជាបង្វេចហើយចេញយាត្រាទៅជាមួយនឹងគូស្នេហាក្នុងរាត្រីនោះ។

Next morning **Soben** said goodbye to White Monkey King and then continued his journey to **Chentak Borei** kingdom. Upon arriving there, he went to ask an old lady for a few-day stay. The old lady agreed and got servants to prepare food and bed for **Soben**. The old lady asked **Soben** about his background and the main purpose for which he was coming. **Soben** told the old lady everything even the fact that he had met the princess in the park. The old lady, the matchmaker, who had already understood the princess, agreed to help **Soben**. The young man could meet the princess in her castle as what he needed. The unmarried couple had an unforgettable sweet love relationship with each other. "My dear! I have to leave here by the junk at this midnight; go away with me?" **Soben** persuaded. The princess hesitated for fear that her father would be profoundly sad when he was separated from his daughter. But since she cared about her future, she agreed to go with her unmarried husband. She collected some valuable things in a bag and left with her husband that night.



រាត្រីនោះ **សុបិន** នាំព្រះនាងទៅដល់សំពៅក៏ស្រាប់តែមានអាមាត្យម្នាក់ចេញមកទទួលព្រះនាងធ្វើឱ្យទ្រង់របូតបង្វេចធ្លាក់ទៅក្នុងទឹក។ **សុបិន** ឃើញដូច្នេះក៏លោតចុះទឹកមុជរកបង្វេចនោះ។  ពួកអាមាត្យក្បត់ក៏នាំព្រះនាងចូលសំពៅហើយប្រញាប់ស្រាវយុថ្កាបើកសំពៅចេញទៅដោយរួសរាន់នាំយកព្រះនាងទៅថ្វាយស្ដេច **បរន្តបៈ**។ ព្រះនាងឃាត់ថា "ព្រះស្វាមីមិនទាន់ឡើងមកទេ សូមកុំអាលចេញទៅអី" ប៉ុន្តែគ្មាននរណាម្នាក់ស្តាប់ពាក្យអង្វររបស់ទ្រង់ឡើយ។ បន្ទាប់ពី **សុបិន** ងើបពីទឹកឡើងវិញ ក៏ស្រាប់តែស្ងាត់ជ្រាបរកសំពៅមិនឃើញក៏យល់ថាខ្លួនចាញ់បោកបញ្ឆោតគេហើយក៏យំសោកស្តាយព្រះរាជធីតាជាគូបណ្តូលចិត្តព្រះនាងមុខជាព្រះកន្សែងសោយសោកពីការព្រាត់ប្រាសនេះជាមិនខាន។

**នៅមានត**

That night, when **Soben** and the princess were at the junk, there suddenly came a royal guard to welcome her. This rapid emerge made the princess slip her bag into the water. Seeing this, **Soben** dived into the water for the bag. All the treacherous royal servants took the princess into the junk and hurriedly raised the anchor and set sail to take the princess to King **Parontak Pak**. "My husband is not yet here; don't leave," begged the princess. But no one listen to her request. Swimming to the surface of the water, it has been silent. He did not see his junk. Knowing that he was  cheated, **Soben** cried bitterly for his dearest princess, who must be weeping and wailing because of this separation.

**(To be continue)**

Reading Book

ពិភពរឿងនិទាន

*The World of Stories*

# សុបិនកុមារ

# Soben Komar



ភាគបញ្ចប់

48

សៀវភៅជាឃ្លាំងនៃចំណេះដឹង

*Books are the source of knowledge*

លុះ **សុបិន** ស្បើយពីទុក្ខព្រួយក៏ទៅជួបស្តេចស្វាស១សួរថា "ហេតុដូចម្តេចបានជាអ្នកមកកាន់ទីនេះទៀត?" **សុបិន** សាសព្ទប្រាប់ស្តេចស្វាសគ្រប់ប្រការ។ ស្តេចស្វាសបានលួងលោម **សុបិន** ថា "សម្លាញ់អើយ ! សូមអ្នកកុំកើតទុក្ខអីខ្ញុំអាចជួយអ្នកបាន"។ ស្តេចស្វាសប្រគល់ទូកមួយទៅ **សុបិន** ហើយផ្តាំថា "សូមអ្នកជិះទូកនេះទៅទិសខាងជើងឈាងខាងកើត អ្នកនឹងបានទៅដល់កោះមួយហៅថា កោះឧទុម្ពរ អ្នកនឹងបានឃើញដើមឧទុម្ពរមួយដើមធំមានផ្លែទុំពណ៌ក្រហម។ នៅទីនោះមានសុករ(ជ្រូក)មួយពាំកែវមណីមករើសផ្លែឧទុម្ពរទុំ១ស៊ី ធ្វើយ៉ាងណាអ្នកយកកែវមណីនោះឱ្យបានហើយអ្នកធ្វើដំណើរទៅទិសនិរតី នឹងបានទៅដល់នគរមួយឈ្មោះ ទណ្ឌកនគរ ចេញទៅទៀតនឹងបានទៅដល់ កុម្ភិនគរ ហើយបន្តដំណើរទៅទៀតនឹងបានដល់ ភេរិតលនគរ និង អសិបត្តលនគរ។ ក្នុងនគរទាំងនោះមានវត្ថុវិសេស១អស្ចារ្យណាស់ ចូរអ្នករិះរកមធ្យោបាយយ៉ាងណាយកវត្ថុទិព្វទាំងនោះឱ្យបានសឹមអ្នកទៅនគរកោសម្ពី អ្នកនឹងបានសោយរាជ្យសម្បត្តិជាស្តេចឯករាជ្យមានកិត្តិនាមល្បីខ្ចរខ្ចាយ។

When **Soben** got off the worry, he went to meet White Monkey King. "Why do you still come back here?" White Monkey King asked. **Soben** told his stories to White Monkey King in details. "Buddy, don't worry; I can help you," said White Monkey King to console **Soben**. White Monkey King gave a boat to Soben and said: "Row the boat northeast, then you will arrive at an island called **Udompor**. There you will see a big Udompor tree bearing red fruits. And there is also a swine (pig) living on this island. This swine has a crystal ball in his mouth and would always go to the tree to eat the fruit. No matter what you do, you have to get this crystal ball. Then take your journey southwest; you will arrive at a kingdom known as **Doandoek** Kingdom. Going ahead, you will reach another kingdom called **Kumpheak** Kingdom.

Leaving this kingdom, you will reach **Pheritaklak** Kingdom and later **Asepaktalak** Kingdom. All of those kingdoms own a lot of magic things. Guy! Do whatever you can to have them before you resume your journey to **Korsampi** Kingdom. Then you will take the throne as a famous and glorious independent king."



**សុបិន** បានថ្លែងអំណរគុណដល់ស្តេចស្វាស ហើយចុះទូកដែលពេញទៅដោយផ្លែឈើនានាជាស្បៀងសម្រាប់ធ្វើដំណើរ។ ពេញមួយថ្ងៃទើប **សុបិន** ទៅដល់កោះឧទុម្ពរហើយឡើងទៅពួននៅប្រគាបឈើចាំមើលសុករ។ មួយស្របក់ក្រោយមក គេក៏ឃើញសុករនោះពាំកែវមណីដើរលើផ្ទៃសមុទ្រឡើងលើកោះខ្ទាក់កែវមណីដាក់ក្បែរគល់ឧទុម្ពរហើយរើសផ្លែទុំៗស៊ីរហូតដល់ឆ្អែត ទើបវាប្រាស់ខ្លួនដេកក្បែរកែវមណីនោះលក់ទៅ។ **សុបិន** យល់ថាសុករដេកលក់ប្រាកដហើយក៏ចុះសន្សឹមៗឆក់យកកែវមណីរបស់ជ្រូកចេញទៅ។ បន្ទាប់ពីបានកែវមណីនោះហើយ **សុបិន** មានអារម្មណ៍ចម្លែកថា ខ្លួនរបស់គេស្រាលដូចសំឡីអាចហក់ឡើងទៅលើមែកឈើខ្ពស់ៗបានយ៉ាងងាយ។ លុះមហាសុករភ្ញាក់ឡើងបាត់កែវមណីខឹងចិត្តណាស់ ក៏បោកក្បាលនឹងគល់ឧទុម្ពរនោះស្លាប់ទៅ។

**Soben**, soon after paying his thankfulness to White Monkey King, got onto the boat which carried lots of fruits, the food for his journey, and rowed away. Upon arriving at **Udompor** Island, **Soben** did as White Monkey King had told him. He climbed up the tree and hid himself on the fork branch waiting to see the swine. Soon the swine, carrying in its mouth a crystal ball, emerged walking on the sea surface, landing on the island and spitting the crystal ball by the base of the **Udompor** tree. The swine browsed fruits until it was full. Then it laid down and slept near the crystal ball. Thinking that the swine was in a deep sleep, **Soben** carefully came down to grasp the crystal ball. With the ball, **Soben** felt so strange and his body was as light as rain; he could leap high very easily, even up to the top of the tree. When the swine woke up and discovered that its crystal ball was lost, it was absolutely furious. It banged its head badly against the base of the tree and then passed away.





**សុបិន** ដើរលើផ្ទៃទឹកលឿនដូចហោះអស់ចំងាយ៣០យោជន៍ទើបបានទៅដល់ទណ្ឌកនគរ។ កាលណោះពួកអ្នកស្រុកនាំគ្នាភ្ញាក់ផ្អើលឆោឡោគ្រប់ៗគ្នា ព្រោះឃើញមនុស្សអាចដើរលើទឹកបានយ៉ាងអស្ចារ្យខ្ចរខ្ចាយល្បីដល់ស្តេចទណ្ឌកនគរ ទើបទ្រង់ហៅ **សុបិន** ចូលគាល់។ **សុបិន** បានចូលទៅថ្វាយបង្គំព្រះរាជាៗត្រាស់សួរថា "នែចៅមាណព ! ដោយអនុភាពអ្វីទៅបានជាឯងអាចដើរលើផ្ទៃទឹកហើយមិនលិចលង់បែបនេះ?" **សុបិន** ទូលថា "សូមទ្រង់មេត្តាប្រោសដោយអនុភាពនៃកែវមណីនេះ ក្រាបទូល"។ ព្រះរាជាមានព្រះទ័យចង់បានកែវមណីនេះណាស់ ទើបទ្រង់ត្រាស់ថា "យើងសុំប្តូរដើបងទិព្វនឹងកែវមណីរបស់ឯងតើបានដែរឬទេ?"

**សុបិន** ទូលថា "ចុះដំបងទិព្វនេះមានអនុភាពដូចម្ដេចខ្លះ?" ស្ដេចពន្យល់ថា "ដំបងនេះស័ក្ដិសិទ្ធិណាស់ បើមនុស្សឬសត្វចង់ប៉ងចូលមកប្រទូសរ៉ាយនឹងយើងៗគ្រាន់តែចាប់ដំបងចង្អុលទៅសត្រូវៗនោះនឹងស្លាប់មួយរំពេច"។ **សុបិន** ទូលតបថា "សូមទ្រង់មេត្ដាប្រោស ទូលព្រះបង្គំមិនហ៊ានប្ដូរនៅទីនេះទេ ត្បិតទូលបង្គំមានតែម្នាក់ឯង លុះត្រាតែព្រះអង្គនឹងទូលបង្គំចូលទៅក្នុងព្រៃរួចសឹមប្ដូរគ្នាទើបបាន ក្រាបទូល"។ ដោយព្រះរាជាចង់បានដួងកែវមណីនោះពន់ពេកក៏ព្រមយាងទៅក្នុងព្រៃហើយប្រគល់ដំបងទិព្វឱ្យទៅ **សុបិន**។ ស្ដេចត្រាស់ថា "នែចៅមាណព ! ចូរអ្នកថ្វាយកែវមណីមកឱ្យយើង"។ **សុបិន** ទូលថា "បពិត្រមហារាជទូលបង្គំមិនថ្វាយកែវមណីឱ្យទ្រង់ឡើយ" ស្ដេចត្រាស់ថា "បើអ៊ីចឹងប្រគល់ដំបងទិព្វឱ្យមកយើងវិញ"។ **សុបិន** ទូលថា "សូមស្ដេចយាងទៅវិញចុះបើបង្ខំទូលបង្គំនឹងថ្វាយចុងដំបងទិព្វនេះ"។

**Soben** walked on water as quickly as a wink. He spent 30 **Youches** (one Youch is roughly equivalent to 16 kilometer) traveling to **Doandoek** Kingdom. At that time, the folks were very amazed to see a man who could walk on water surface. It was so great that this news was known to the king, who ruled the kingdom. The king invited **Soben** to have an audience with him. **Soben** paying his salutation to the king, the king asked, "Gentleman! What power enables you to walk on water?" **Soben** replied, "It is from the power of this crystal ball, My Majesty!" The king, then, longed for the crystal ball. "I was wondering if we could exchange my magic wand with your crystal ball?" requested the king. "What can your magic wand do?" **Soben** asked. The king explained, "This wand is very powerful. If you are attacked by an enemy, just point it at your enemy, he or she will die suddenly." **Soben** replied, "My majesty! I'm afraid that I can't exchange them here because I am alone. But if only you and I go into the forest the exchange can be possible." Really eager to get the crystal ball, the king agreed to go into the woods and handed his wand to **Soben**. "Gentleman, give your crystal ball to me!" requested the king. **Soben** replied, "My majesty! I cannot give you my crystal ball." The king said, "If not, return the magic wand to me!" **Pundit Soben** answered, "Please go back to your palace. If you coerce me, I'll point this wand at you."

ស្តេចទណ្ឌកនគរមិនបានកែវមណីហើយ ថែមទាំងបាត់បង់ដំបងទិព្វទៀត។ ទ្រង់ស្តាយក្រោយដោយយាងត្រឡប់ទៅវិញដោយព្រះហស្តទទេ។ ឯ **សុបិន** បានចេញពីព្រៃធ្វើដំណើរទៅមុខទៀតអស់ចំងាយ៣០យោជន៍ទើបទៅដល់កុម្ភិនគរ គេបានសំដែងឫទ្ធិលើផ្ទៃទឹកតាមដងទន្លេចូលទៅក្នុងនគរនោះ។ អស់មហាជនបានឃើញ **សុបិន** ក៏ភ្ញាក់ផ្អើលជាខ្លាំង។ ស្តេចកុម្ភិនគរកាន់ក្អមទឹកយាងទៅទន្លេគង្គាបានត្រាស់សួរ **សុបិន** អំពីដំណើរដែលអាចដើរលើផ្ទៃទឹកបាន។ **សុបិន** បានបង្ហាញដួងកែវមណីដែលមានរស្មីភ្លឺផ្លេកចិញ្ចាចចិញ្ចែង។ ព្រះរាជាទតឃើញទ្រង់សព្វព្រះរាជហឫទ័យណាស់ ទើបត្រាស់សុំប្តូរនឹងឆ្នាំងទិព្វរបស់ទ្រង់។ **សុបិន** ទូលសួរព្រះអង្គអំពីអានុភាពនៃឆ្នាំងទិព្វនេះ។ ព្រះរាជាត្រាស់ថា "ឆ្នាំងទិព្វនេះមានអានុភាពច្រើនប្រការ បើត្រូវការអាហារគ្រាន់តែផ្អៀងឆ្នាំងនឹងចេញអាហារផ្សេងៗតាមចំណង់ បើមានពួកសត្រូវចូលមកយាយី គ្រាន់តែផ្កាប់ឆ្នាំងនេះនឹងបណ្តាលជាទឹកជំនន់លិចលង់ពួកសត្រូវស្លាប់អស់មិនខាន។ **សុបិន** ទូលថា "សូមទ្រង់មេត្តាប្រោស បើទ្រង់សព្វព្រះទ័យនឹងកែវមណីនេះ លុះតែទ្រង់យាងចូលទៅក្នុងព្រៃតែពីរនាក់ទើបទូលបង្គំសុខចិត្តប្តូរថ្វាយ"។ ដោយព្រះរាជាចង់បានកែវមណីនេះខ្លាំងពេក ទើបស្តេចយាងចូលក្នុងព្រៃ។ លុះដល់ព្រៃស្ងាត់ **សុបិន** ក៏ប្រើល្បិចដូចមុនយកក្អមបានអំពីព្រះរាជាក្នុងព្រៃនោះ។

The king of **Doandoek** Kingdom got neither the crystal ball nor his magic wand. He was very regretful that he returned to his palace with nothing. As for **Pundit Soben**, he left the forest and took his journey for another 30 Youches. Then he reached the kingdom of **Kumpheak**. He had shown himself off by walking on a river. All the folks, seeing his performance, were very surprised. This news came to the ear of the king of **Kumpheak** Kingdom. One day, with a clay pot in his hand, the King went to Kongkea River and asked **Pundit Soben** about the fact that he could walk on water. **Pundit Soben** showed his brilliant crystal ball. No sooner did the king see it than he was very satisfied with it. The king suggested **Pundit Soben** on exchanging the crystal ball with his magic clay pot.



**Pundit Soben** asked the king about the power of the magic clay pot. "This magic pot is very powerful. If you need food, you merely lean this pot, and then food will come out as you wish. If an enemy is attacking you, simply turn upside down; then, it causes flood, killing them all," the king told. **Pundit Soben** replied, "My majesty! If you need my crystal ball, only you go into the forest will I exchange it with your pot." Due to his strong desire for the crystal ball, the king went into the forest alone. Upon arriving in the quiet forest, **Pundit Soben** used the same trick and gained the clay pot from the king.

**សុបិន** បានក្អមទិព្វហើយក៏ចេញដំណើរតទៅទៀតអស់ចំងាយ៣០យោជន៍ទើបទៅដល់ភេរិតលនគរ។ នៅនគរនេះមានស្គរទិព្វវិសេសមួយ នៅផ្ទៃស្គរម្ខាងសម្រាប់វាយបណ្តេញខ្មាំងសត្រូវឱ្យរត់ខ្ចាត់ខ្ចាយ នៅផ្ទៃម្ខាងទៀតសម្រាប់វាយបង្កើតវត្ថុផ្សេងៗតាមតម្រូវការ។ **សុបិន** បានប្រើមធ្យោបាយដណ្តើមយកស្គរនោះដូចមុនៗដែរ។ បន្ទាប់មក **សុបិន** បានចេញដំណើរទៅទៀតដល់អសិបត្តនគរ។ នៅនគរនោះមានដាវទិព្វមួយអាចកាត់ក្បាលសត្រូវបានគ្រប់ទិសទី **សុបិន** បានប្រើមធ្យោបាយបោកបញ្ឆោតស្តេចនគរនោះយកដាវទិព្វបានដូចមុនដែរ។ **សុបិន** ធ្វើដំណើរអស់ចំងាយ៣០យោជន៍ទើបទៅដល់នគរកោសម្ពីហើយឈាងចូលអារាមដើម្បីនមស្សការគ្រូឧបជ្ឈាយ៍ និងអាចារ្យដោយការគោរព។

**Soben**, having had the magic clay pot in his hand, continued journey. Traveling for 30 Youches, he arrived at **Pheritaklak** Kingdom. In this kingdom, there was a magic drum. One side of the drum, when beaten, could defeat enemy, while beating the other side could make up a lot of things as needed. **Soben** used the same trick to have the drum. After getting the drum, **Soben** traveled ahead until he arrived at **Asepaktalak** Kingdom. In this kingdom there was a magic sword which was able to cut everything. **Soben** employed the same deception to successfully gain that magic sword from the king in that kingdom. Traveling for the other 30 Youches, **Soben** arrived at **Korsampi** Kingdom, so he came around his pagoda to pay respect to Master and Buddhist priest.



និយាយពីព្រះនាង **បុទ្មកេសរា** អស់រយៈពេលបីខែទើបមកដល់នគរកោសម្ពី។ ពួកអាមាត្យហែហមព្រះនាងចុះពីសំពៅនោះ ព្រះនាងសួរអាមាត្យថា "ឯណាព្រះស្វាមីខ្ញុំ?" អាមាត្យកុហកព្រះនាងថា "**សុបិន** មកតាមសំពៅក្រោយ សូមព្រះនាងយាងទៅរង់ចាំក្នុងព្រះរាជវាំងសិនចុះ"។ ព្រះនាងបានស្បើយពីទុក្ខព្រួយបន្តិចដោយជឿតាមពាក្យបញ្ឆោតរបស់ពួកអាមាត្យទាំងនោះ។ អាមាត្យនាំព្រះនាងទៅថ្វាយព្រះរាជា។ទ្រង់ទតឃើញរូបឆោមព្រះនាងភ្លាមក៏សព្វព្រះរាជហឫទ័យពន់ពេក។ គ្រានោះ ព្រះនាងត្រាស់សួរអាមាត្យទៀតថា "ឯណាព្រះស្វាមីខ្ញុំ?" អាមាត្យទូលថា "ព្រះរាជាអង្គនេះហើយជាព្រះស្វាមីរបស់ទ្រង់"។ ព្រះនាងក៏យល់ថា ទ្រង់ត្រូវពួកអាមាត្យបោកបញ្ឆោតហើយ ក៏ទ្រង់ព្រះចិន្តាកើតទុក្ខចុកណែនឱរ៉ា។ ទ្រង់ព្រះកន្សែងពិលាបរៀបរាប់ដោយប្រការផ្សេងៗដោយព្រាត់ពីព្រះវរមាតាបិតា និងព្រះស្វាមីបណ្តូលចិត្ត។ ព្រះរាជាទ្រង់បានលួងលោមសំណេះសំណាលនឹងព្រះនាងៗខ្ពាញ់ណាស់អត់ទ្រាំពុំបានក៏តិះដៀលបន្តុះបង្អាប់ធ្វើឱ្យព្រះរាជាឈឺចាប់មិនហ៊ានចូលជិតព្រះនាងឡើយ។

Back to Princess **Botumkesora**, it took her for three months to arrive at **Korsampi** Kingdom. Royal guards were accompanying her when she was getting out of the junk. **Botumkesora** asked one guard, "Where is my husband?" "**Soben**, your husband, will come on the next junk; please, Princess, go into the royal palace," replied the guard. She, then, was quite relieved, believing what the guard had told her. The royal guard took **Botumkesora** to see the king who quickly fell in love with her as soon as he saw her beauty. At that time, she repeated her question, "Where is my husband?" The guard told, "This king is your husband." The princess was aware that she was cheated, so she was very sad and sorrowful. She wailed and wept recounting her stories of separation from her parents and her beloved husband. Seeing this, the king came to console her, but she attached such a strong antipathy that she swore bad words, which made the king dare not approach her.



កាលណោះមានអាមាត្យម្នាក់ចេញពីសំពៅក្រោយគេ ហើយបានឈោងចូលទៅក្នុងអារាមនោះស្រាប់តែបានឃើញ **សុបិន** កំពុងលេងអុកលើសាលាក៏សួរថា "អ្នក **សុបិន** ! តើអ្នកមកដល់តាំងពីអង្កាល់?" **សុបិន** ថា "ខ្ញុំមកដល់ពីរ-បីថ្ងៃហើយ"។ អាមាត្យថា "ចុះអ្នកមកដោយសារអ្វី" **សុបិន** ថា "ខ្ញុំដើរមកតែម្នាក់ឯង"។ អាមាត្យស្តាប់ឮហើយក៏ស្ញប់ស្ញែងពីឫទ្ធិចេស្តានៃ **សុបិន** ហើយសួរទៀតថា "អ្នកបានមកដល់នគរមុនខ្ញុំ ចុះអ្នកបានចូលគាល់ព្រះករុណាហើយឬនៅ?" **សុបិន** ថា "ខ្ញុំមិនស្គាល់ព្រះរាជាទេ"។ អាមាត្យស្តាប់ហើយក៏ទៅទូលព្រះមហាក្សត្រ។ ទ្រង់បញ្ជាអាមាត្យទៅហៅ **សុបិន** ចូលគាល់ តែ **សុបិន** ប្រាប់អាមាត្យវិញថា "យើងស្គាល់តែព្រះរាជាណាដែលមានទសពិធរាជធម៌តែប៉ុណ្ណោះ ឯព្រះរាជាគ្មានទសពិធរាជធម៌យើងមិនស្គាល់ទេ ចូរអ្នកវិលទៅទូលព្រះអង្គវិញចុះ" អាមាត្យទូលព្រះអង្គតាមពាក្យ **សុបិន** ប្រាប់។ ព្រះរាជាទ្រង់ពិរោធខ្លាំងណាស់ក៏ត្រាស់បង្គាប់សេនាបតីឱ្យលើកទ័ពទៅចាប់ **សុបិន** ក្នុងអារាម។ លុះកងទ័ពព័ទ្ធជុំវិញអារាមទើប **សុបិន** លើកដំបងទិព្វចង្អុលទៅកងទ័ពទាំងនោះបណ្តាលឱ្យកងទ័ពទាំងអស់ដួលសន្លប់គរលើគ្នាដូចដើមចេកដែលត្រូវខ្យល់ព្យុះបក់បោក។

At that time, there was a royal guard who departed his junk the last of all. When he arrived back in his kingdom, he paid a short visit on the pagoda where **Soben** had stayed in and was visiting too. There the guard saw **Soben** playing chess in the monastery. He asked, "**Pundit Soben**! When did you arrive here?" "I arrived here two or thee days ago," replied the **Pundit Soben**. "How did you come here?" added the guard. "I arrived here on foot," replied **Soben**. Having heard this, the royal guard was very complimentary to the power of **Soben**. He asked, "You arrived here before me; have you had an audience with the king yet?" **Soben** replied, "I don't know who the king is." After hearing this, the royal guard went to inform the king about that. The king then ordered his royal guards to get **Soben** to have an audience with him. **Soben** replied, "I have an audience with the king who possesses qualifications as a king only; I would not have an audience with any king who doesn't have these qualifications.



Please go and inform your king about that." The royal guards told the king what **Soben** had said. The king was so furious that he ordered his soldiers to arrest **Soben**. The soldiers surrounded the pagoda. Seeing this, **Soben** raised his magic wand and pointed it at those soldiers, so they fell down widely like banana trees battered by a storm.

ក្នុងចំណោមទ័ពទាំងអស់ មានតែសេនាបតីមួយរស់រួចជីវិតរត់ចូលទៅទូលព្រះរាជាឱ្យទ្រង់ជ្រាបពីព្រឹត្តិការណ៍នេះ។ ព្រះរាជាទ្រង់ក្រេវក្រោធមហិមា ទ្រង់ចាត់ចែងចតុរង្គសេនាលើកទ័ពចេញទៅដោយព្រះអង្គឯង។ **ចៅសុបិន** បានដឹងថា ព្រះរាជាទ្រង់លើកទ័ពធំសំបើមមកប៉ងពិឃាតដូច្នេះ ទើបទូងស្គរបង្កើតវិមានយ៉ាងចិញ្ចាចចិញ្ចែង ព្រមទាំងកំពែងប៉មប្រាការព័ទ្ធជុំវិញ។ ព្រះរាជាទ្រង់បញ្ជាឱ្យទ័ពដំរីចូលព្រេចកំទេចកំពែងបន្ទាយឱ្យខ្ទេច តែឥតបានលទ្ធផលអ្វីឡើយ។ ទ្រង់មិនអស់ព្រះទ័យក៏បញ្ជាឱ្យពលសេនាទាំង៤ទិសឡើងកំពែងប៉មចូលទៅព្រមគ្នា។ **ចៅសុបិន** នៅលើវិមានប្រាសាទថ្នាក់លើបង្អស់ បានមើលឃើញពួកពលសេនាព្រះរាជាច្រើនណែនណាន់តាន់តាប់កំពុងនាំគ្នាពុះពារឡើងកំពែងនិម្មិតទាំង៤ទិស។ **ចៅសុបិន** ឃើញដូច្នេះឥតមានភិតភ័យអ្វីឡើយ ហើយបង្គាប់ពួកនារីឱ្យប្រគំបទភ្លេងច្រៀងរាំយ៉ាងអធិកអធម។

Only one commanding officer was alive and went to tell the king about this. The king was absolutely furious and rallied around troops from the four directions and led them by himself. **Soben**, knowing that the king led an enormous fighting troops aimed at killing him, beat the drum to conjure a magnificent castle gleaming with lights and with massive walls around it. The king ordered the troops to drive elephants forward in order to destroy the surrounding wall, but did not have success. Not admitting the failure, the king ordered his troops to climb up the wall at once. **Soben** stood on the highest floor of the castle; he saw crowd of royal troops climbing up the conjured wall on the four directions. This could not make **Soben** frightened; rather, he ordered the ladies to excellently play music and dance.



ព្រះរាជាត្រាស់បង្គាប់ពួកសេនាបតីថា "ពួកយើងចាប់អា **សុបិន** សម្លាប់ចោលហើយយកវាទៅឱ្យសត្វក្អែកត្មាតស៊ីកុំត្រាប្រណី"។ **ចៅសុបិន** ឃើញដូច្នេះ ក៏លើកដំបងទិព្វចង្អុលទៅកងចតុរង្គសេនា ធ្វើឱ្យកងពលទាំងអស់នោះធ្លាក់រពុយទៅដីសន្លប់គរលើគ្នាហាក់ដូចជាស្រមោចត្រូវរោលដោយកំដៅភ្លើងដូច្នោះដែរ នៅសល់តែព្រះរាជា សេនាបតី និងលោកបុរោហិតប៉ុណ្ណោះ។ អ្នកទាំងបីបិតលើដំរីមានក្តីភិតភ័យរន្ធត់ស្ទើរធ្លាក់ដាំដូងពីលើដំរី ទើបប្រញាប់នាំគ្នាលើកដៃសំពះអង្វរសូមឱ្យ **ចៅសុបិន** លើកលែងទោសទុកជីវិត។ **ចៅសុបិន** ឃើញដូច្នេះ ក៏មានចិត្តអាណិតមេត្តាទើបទូលព្រះអង្គថា "បពិត្រមហារាជ ទូលព្រះបង្គំមិនពិឃាតទ្រង់ទេ"។ ហើយ **ចៅសុបិន** យាងទ្រង់ទៅកាន់វិមាននិម្មិតរបស់គេ។ ខណៈពេលនោះ ព្រះរាជា និង **ចៅសុបិន** បានធ្វើសច្ចាស្បថលែងប្រទូសរ៉ាយនឹងគ្នាទៀតហើយ។

"Let's catch **Soben** and brutally slaughter him as feed for crows and vultures," said the king to his royal troops. Seeing this, **Soben** pointed his magic wand at the four-division troops causing them one by one fall down on the ground unconsciously, building up on one another like ants climbing up the wall were being burned down and fell, except for the king, the troop commander and the Brahman priest, who were driving their elephant. They are so scared that they could almost fall off the elephant's back, and therefore they put their palms together and raised them up to beg **Soben** for their lives. This made **Soben** feel pity for them. "My majesty! I don't kill you," **Soben** said, and then returned to stay in his conjured castle. At that time, the king and **Soben** swore to stop fighting against each other.



ព្រះរាជាមានព្រះឱង្ការថា "**ចៅសុបិន ! បុទុមកេសរា** នឹករលឹកដល់ឯងខ្លាំងណាស់ នាងកំពុងតែព្រះកន្សែងក្នុងរាជវាំងឯណោះ នាងឥតមានចិត្តត្រេកត្រអាលជាមួយនឹងយើងទេ ឱ្យតែឯងទុកជីវិតឱ្យយើងហើយស្រោចស្រង់ជីវិតដល់ពួកពលទាំងអស់ឱ្យមានជីវិតឡើងវិញ យើងសុខចិត្តប្រគល់រាជសម្បត្តិ ហើយរៀបពិធីអភិសេកឯង និងព្រះនាង **បុទុមកេសរា** ឱ្យគ្រងរាជ្យនៅកោសម្ពីនគរនេះ"។ **ចៅសុបិន** បានប្រតិបត្តិតាមព្រះរាជបញ្ជាដោយសេចក្ដីគោរព។ ចតុរង្គសេនាទាំងសត្វទាំងមនុស្សក៏រស់ឡើងវិញទាំងអស់។ ព្រះរាជាត្រាស់បញ្ជាអាមាត្យឱ្យទៅដង្ហែព្រះនាង **បុទុមកេសរា** យាងមកវិមាននិម្មិតនេះ។ ព្រះនាងបានជួបព្រះស្វាមីមានសេចក្ដីត្រេកអរមហិមាស្ទុះទៅឱបព្រះស្វាមីដោយក្ដីរំភើប និងតក់ស្លុតក្រៃលែង។ ហើយព្រះរាជាធ្វើពិធីរាជាភិសេក **ចៅសុបិន** ជាមួយព្រះនាង **បុទុមកេសរា** ឱ្យឡើងគ្រងរាជ្យជាស្ដេចផែនដីតំណពីព្រះអង្គ ហើយទ្រង់ថ្វាយព្រះនាមថា "**ព្រះបាទសុបិនរាជ**"។

The king said: **Pundit Soben**, **Botomkesara** was missing you so much that she was wailing and weeping in the royal palace. She is not happy for me. If you agree not to kill me, and bring all of my troops back to life, I will marry **Botomkesara** to you and put you on my throne to be the king of Korsampi Kingdom. **Soben** respectfully obeyed the king's order. The four-division troops and animals were brought back to their lives. The king ordered the royal servants to march in procession to invite **Botomkesara** to the conjured castle. Seeing her husband, the princess was extremely happy and went to hug him with great excitement and surprise. Then the king agreed to hold the coronation of Pundit Soben, called **King Soben Reach**, and **Queen Botomkesara.**



ថ្លែងពីចិន្តបុរីដែនខេមរដ្ឋ  បន្ទាប់ពីបាត់ព្រះរាជធីតាពីកាឡាបន្ទំទៅហើយ ក៏កើតជ្រួលច្របល់ឡើង។ ព្រះរាជាចាត់ពួកអាមាត្យឱ្យរុករកសព្វនាវានៃស្តេច ១០១។ តែការស្វែងរកនេះឥតបានលទ្ធផលអ្វីបន្តិចឡើយ តែមានដំណឹងថា សំពៅទាំង៧របស់ពួកឈ្មួញបានពង្រាត់ព្រះរាជធីតាទៅជាមួយបាត់ទៅហើយ។ ព្រះរាជាទ្រង់បានចាត់សំពៅជាច្រើនចេញទៅធ្វើជំនួញគ្រប់ប្រទេសនានាដើម្បី ស៊ើបរកព្រះរាជធីតា។ ក្នុងចំណោមសំពៅទាំងអស់នោះ មានសំពៅមួយបានទៅ ដល់នគរកោសម្ពី ហើយទទួលដំណឹងថា មានព្រះមហាក្សត្រមួយអង្គទើបនឹង គ្រងរាជថ្មីៗជាមួយព្រះអគ្គមហេសី **បុទុមកេសរា** ជាព្រះរាជធីតានៃក្រុងចិន្តបុរី។ អាមាត្យនាយសំពៅបានដឹងពីព័ត៌មាននេះច្បាស់ហើយ ទើបចាត់ចែងគ្រឿង បណ្ណាការមានតម្លៃផ្សេងៗចូលគាល់ព្រះរាជទេវី។ លុះអាមាត្យបានជួបព្រះរាជ ធីតាហើយក៏ក្រាបទូលព័ត៌មាននេះដល់ស្តេចក្រុងចិន្តបុរី។ ចំណែកព្រះនាង **បុទុមកេសរា** វិញក៏បានក្រាបទូលព័ត៌មាននេះដល់ព្រះរាជស្វាមីដែរ។

Back to **Chentak Borei**, Kingdom of Cambodia, having known that the princess was not in her bed chamber, everyone was filled with panic. The king ordered his royal servants to search for the princess in every junk of 101 kings, but to no avail. It was said that the prince must have been abducted by the merchants of the seven junks. The king got many junks to trade in lots of kingdoms in search of his daughter. One of the junks reached Korsampi Kingdom and they heard that there was a king and a queen, named **Botomkesara**, the princess of **Chentak Borei** kingdom, newly coming to the throne in this kingdom. Discovering that it was clearly true, the royal servants and the merchant managed to wrap up presents of valuable jewelry to ask for an audience with the Queen in order to see her. Seeing the princess personally, they turned back and informed the king of **Chentak Borei** about his daughter. Anyway, Queen **Botomkesara** also told her husband about that.



**ព្រះបាទសុបិនរាជ** បានផ្ញើរាជសារមួយច្បាប់ថ្វាយដល់ព្រះវរមាតា-បិតាក្មេក ក្នុងរាជសារនោះមានសេចក្តីថា "ទូលព្រះបង្គំ **ព្រះបាទសុបិនរាជ** សូមថ្វាយបង្គំព្រះវរមាតានិងបិតា សូមទ្រង់ព្រះរាជទានទោសចំពោះទូលព្រះបង្គំដែលនាំគ្នារត់ចោលព្រះអង្គដោយមិនបានទូលថ្វាយ ទាំងនេះជាកំហុសធំណាស់ សូមព្រះអង្គអភ័យទោសឱ្យពួកយើងទាំងពីរនាក់ផង"។ ព្រះបាទក្រុងចិន្តបុរីបានទទួលដំណឹងនេះហើយ ទ្រង់មានព្រះទ័យក្រេវក្រោធជាខ្លាំងប្រុងលើកទ័ពទៅប្រយុទ្ធជាមួយ **ព្រះបាទសុបិនរាជ** តែអាមាត្យនិងពួកឈ្មួញទាំងនោះបានក្រាបទូលជំទាស់ថា "សូមទ្រង់កុំលើកទ័ពទៅប្រយុទ្ធនឹងស្តេចនោះអី កុំថាឡើយមនុស្សលោកទោះជាទេវតាក៏មិនអាចយកជ័យជំនះលើស្តេចនគរនោះបានដែរ ព្រោះ**ព្រះបាទសុបិនរាជ** មានអាវុធទិព្វដ៏វិសេសៗច្រើនយ៉ាងដូចជា ដួងកែវមណីទិព្វ ដំបងទិព្វ ឆ្នាំងទិព្វ ស្គរទិព្វ និងដាវទិព្វសុទ្ធតែជាអាវុធមានមហិទ្ធិឫទ្ធិអស្ចារ្យណាស់"។ ព្រះបាទ **កោមលរាជ** ទ្រង់សណ្តាប់យោបល់អាមាត្យហើយ ក៏ទ្រង់មានព្រះទ័យមិនហ៊ានប្រឆាំងនឹង **ព្រះបាទសុបិនរាជ** ឡើយ។ ចាប់តាំងពីពេលនោះមក រវាងនគរទាំងពីរតែងតែទាក់ទងគ្នាទៅវិញទៅមកដោយការគោរពរាប់អាន។

King **Soben Reach** sent his parent-in-laws a royal message saying: I, King **Soben Reach**, would fully express my respect to you, My parent-in-laws. I would like to apologize most sincerely to you for our eloping without informing you. This is a big mistake. May you, father, forgive us. Having read this, the king of **Chentak Borei** was absolutely angry, so he intended to lead the troops to fight against King **Soben Reach**. But the servants and merchants told him that, "My majesty! Don't fight against that king. Neither human beings nor deities will win against him, since King **Soben Reach** has lots of magic weapons like crystal ball, magic wand, magic pot, magic drum and magic sword, which are all the most powerful weapons. " Realizing about this, King Komolreach wouldn't dare fight against King **Soben Reach**. Since then, a good relationship existed between the two kingdoms.



ច្រើនខែក្រោយមកព្រះនាង **បុទុមកេសរា** ទ្រង់ក៏មានព្រះគភ៌។ លុះជិតគ្រប់ទសមាស ព្រះនាងក៏មានបំណងចង់ប្រសូតព្រះរាជបុត្រនៅឯរាជត្រកូល ទើបទ្រង់ទូលបំណងនេះជូនព្រះស្វាមី។ **ព្រះបាទសុបិនរាជ** សម្រេចព្រះទ័យយាងទៅជាមួយព្រះមហេសីដែរ ប៉ុន្តែទ្រង់មិនចង់ធ្វើដំណើរតាមផ្លូវទឹកទេ ដោយទ្រង់ចាត់ចតុរង្គសេនាជង្ហែព្រះអគ្គមហេសីតាមផ្លូវគោក ទើបទ្រង់បញ្ជាដាវទិព្វកាប់ឆ្កាព្រៃជិរះផ្លូវឱ្យបានរាបរយ។ ដាវទិព្វក៏ហោះចេញទៅចាត់ចែងធ្វើផ្លូវតាមព្រះរាជបញ្ជាកាប់ឆ្កាព្រៃពង្រាបដីទួលឬភ្នំ បំពេញទីជំហុកថ្លុក ត្រពាំងឱ្យរាបស្មើ មានទំហំធំទូលាយចាប់ពីនគរកោសម្ពីរហូតដល់ដែនខេមរដ្ឋ។ លុះព្រះសែងដាវទិព្វធ្វើផ្លូវបានសម្រេចហើយទើបត្រឡប់ចូលស្រោមវិញ។ **ព្រះបាទសុបិនរាជ** ទ្រង់បានប្រកាសដល់ប្រជារាស្ត្រនាំគ្នាចេញទៅតាំងរានផ្សារលក់ទំនិញផ្សេងៗនៅតាមផ្លូវមានលក់ម្ហូបអាហារ និងវត្ថុផ្សេងៗតាមចំណង់។ ការធ្វើដំណើរដែលរៀបចំឡើងនូវការហែហមច្រើនណែនណាន់តាន់តាប់។ ពួកពលសេនាយោធាបានសុខសប្បាយបរិបូណ៌ដោយអាហារភាជន៍ និងទឹកប្រើប្រាស់ឥតមានខ្វះអ្វីឡើយ។ ផ្កាំងទិព្វបញ្ចេញអាហារមានឱជារសឆ្ងាញ់ពិសា។ ស្គរទិព្វទទួលភារៈសាងសង់ព្រះពន្លា និងជំរុំយ៉ាងល្អប្រណិត។

Several months later, **Botomkesara** fell pregnant. The time of delivering baby was forthcoming; she wanted to give birth in her royal family, so she told her husband about her purpose. King **Soben Reach** decided to accompany his wife too, but he did not want to take waterway. He wanted his four-division troops to escort him and his wife along the road, so he wielded his magic sword to clear forest for the way. The magic sword was drawn and flew to do its task – clearing the forest, leveling the hill or mountain, filling holes and ponds with earth, making a smooth road from **Korsampi** kingdom to **Chentak Borei**. After a smooth wide road was built, the magic sword flew back into its scabbard.



King **Soben Reach** made a royal announcement to his people that they could sell things along the new road to **Chentak Borei** kingdom as they wanted. The journey was made with a big procession. The troops were safe and sound because they had enough food and water. The magic pot made auspicious food, while the magic drum built nice camps and shelters.



**ព្រះបាទកោមលរាជ** និងព្រះរាជទេវីមានព្រះទ័យសោមនស្សរីករាយណាស់ ទ្រង់បានបញ្ជាសេនាចាត់ចែងធ្វើពិធីទទួលស្វាគមន៍ព្រះរាជបុត្រយ៉ាងឧឡារិក។ បន្ទាប់មក **ព្រះបាទកោមលរាជ** ទ្រង់ធ្វើពិធីរាជាភិសេកតាមប្រពៃណី ទ្រង់បានប្រគល់រាជសម្បត្តិនៃក្រុងចិន្តបុរីព្រះរាជទានដល់ព្រះរាជសុនិសាគ្រប់គ្រងជាតំណព្រះរាជវង្សតរៀងទៅ។ ឯព្រះនាង **បុទុមកេសរា** បានប្រសូតព្រះរាជបុត្រមួយព្រះអង្គ។ ពេលប្រសូតគេបានទទួលព្រះរាជកុមារនឹងស្បែកសីង្ហ ទើបព្រះញាតិសាលោហិតថ្វាយព្រះនាមថា "**សិង្ហនរកុមារ**"។ លុះ **សិង្ហនរកុមារ** ចេះដើរហើយ ព្រះនាងប្រសូតព្រះរាជបុត្រមួយព្រះអង្គទៀតថ្វាយព្រះនាមថា "**កុញ្ញរកុមារ**"។ **ព្រះបាទសុបិនរាជ** បានទំនុកបម្រុងស្តេចស្វាសព្រមទាំងពួកពានរជាបរិវារហើយព្រះអង្គយាងត្រឡប់មកនគរកោសម្ពីវិញ។

## ចប់ដោយបរិបូរណ៍

King **Komolreach** and his wife had a great pleasure; they ordered the royal servants to organize a big party to welcome their son-in-laws and daughter. Then King **Komolreach** traditionally held a coronation ceremony for King **Soben** to rule **Chentak Borei** Kingdom since then. By the way, Princess **Botomkesara** delivered a baby boy. As soon as the baby was born, he was wrapped up with hide of lion. This made his relatives name him "**Singhanorak Komar**". When the little boy could walk, **Botomkessara** delivered another baby boy named "**Konhak Komar**." As for King **Soben Reach**, he provided support for White Monkey King and his retinues everything and then he returned to **Korsampi** Kingdom. **The End**